# ការវះកាត់មហារីកដោះចេញ

**ការវះកាត់មហារីកដោះមានពីរយ៉ាង ហៅថាឡាំពិចតូមីនឹងម៉ាសិចតូមី។**

ម៉ាសិចតូមី គឺជាវិធីវះកាត់យកមហារីកដោះចេញ។ ការវះកាត់នេះធ្វើឡើងដើម្បីព្យាបាល ឬដើម្បីការពារជំងឺមហារីកដោះ។ មានតែអ្នកជំងឺដែលមានគ្រោះថ្នាក់ខ្ពស់ប៉ុណ្ណោះទេ ដែលត្រូវធ្វើការវះកាត់ដើម្បីការពារជំងឺមហារីក។



ជាការធម្មតាទេ ដែលអ្នកខ្លាចកើតមហារីក។ ជំងឺមហារីកដោះ កាលណាត្រូវបានរកឃើញឆាប់ គឺវាងាយព្យាបាលបាន។

មានការវះកាត់ធំៗបួនយ៉ាង ៖

- **ការវះកាត់ដុំសាច់ដុះចេញ -ជាការវះកាត់មួយសំរាប់កាត់យកតែដុំសាច់ដុះចេញប៉ុណ្ណោះ (មិនមែនដោះទេ)។ ជាលិកាធម្មតាតូចមួយនៅជុំវិញដុំសាច់ដុះគឺត្រូវបានគេកាត់ចេញដើម្បីឲ្យដឹងប្រាកដថាកោសិកាមហារីកទាំងអស់នៅកន្លែងកៀនៗ សាច់ដុះនោះក៏ត្រូវបានយកចេញដែរ។**
- **ការវះកាត់ដោះចេញទាំងអស់** - **ការកាត់ចេញនៃសាច់ដោះដែលមានពោគ រួមទាំងចុងដោះផងដែរ។**
- **ការវះកាត់ដោះចេញកែតំរូវទាំងស្រុង** - ការកាត់យកដោះចេញ កាត់យកក្រពេញមានទឹករងៃក្រោមដៃ ហើយជាញយៗតាមជួរ សាច់ដុំទ្រូង
- **ការវះកាត់ចេញទាំងស្រុង** - **ការកាត់យកដោះចេញ កាត់យកក្រពេញមានទឹករងៃ និងសាច់ដុំទ្រូង។ ការវះកាត់ប្រភេទនេះគឺកម្រធ្វើណាស់។**



ប្រភេទនៃការវះកាត់មហារីកដោះគឺអាស្រ័យទៅលើដំណាក់កាលនៃមហារីក, ទំហំនៃដុំសាច់ដុះ, ទំហំនៃដោះ ហើយថាតើកោសិកាមហារីកមាននៅក្នុងក្រពេញមានទឹករងៃក្រោមដៃ ដែរឬទេ។

**ក្រពេញមានទឹករងៃគឺជាផ្នែកមួយនៃប្រព័ន្ធក្រពេញដែលជួយប្រយុទ្ធនិងជំងឺនានា ហើយវាច្រោះសារធាតុដែលមិនត្រូវការ ដូចជាកោសិកាមហារីក និងបាក់តេរី។ កោសិកាមហារីកដែលជាប់នៅក្នុងក្រពេញមានទឹករងៃអាច**

ប្រភេទនៃការវះកាត់ដែលអ្នកនឹងធ្វើគឺអាស្រ័យទៅលើការទទួលយកបានពីសំណាក់អ្នក និងគ្រូពេទ្យរបស់អ្នក។ ស្ត្រីភាគច្រើនតែងតែស្វែងរកការពិគ្រោះយោបល់ទីពីររបស់គ្រូពេទ្យមុននឹងធ្វើការវះកាត់។

ការកែលំអដោះឡើងវិញគឺជាការវះកាត់មួយដែលស្ត្រីអាចជ្រើសយកដើម្បីកែទម្រង់ដោះឡើងវិញក្រោយពីការវះកាត់ដោះចេញរួចហើយ។ ដោះដែលធ្វើឡើងវិញមិនមានភាពសំរើបដូចដោះពីធម្មជាតិទេ តែទោះជាយ៉ាងណាក៏ដោយ ស្ត្រីភាគច្រើនដែលមានដោះធ្វើកែលំអឡើងវិញគេពេញចិត្តនឹងកិច្ចការនោះ។



គ្រូពេទ្យវះកាត់អាចធ្វើការកែលំអរដោះច្រើនប្រភេទ។ស្ត្រីខ្លះជ្រើសរើសការកែរលំអរដោះរបៀបដោះអិមផ្លេនដែលដាក់បំពេញសារធាតិសេលីននឹងសីលឡីកនជេល។

វិធីផ្សេងទៀតគឺប្រើជាលិកាដែលកាត់ចេញពីផ្នែកណាមួយពីរាងកាយអ្នក។គ្រូពេទ្យវះកាត់អាចយកស្បែកសាច់ដុំនឹងខ្លាញ់ពីផ្នែកខាងក្រោមពោះរបស់អ្នកពីខាងក្រោយឬកំប៉ះគូទ។

ការកែលំអដោះឡើងវិញអាចធ្វើឡើងក្រោយពីការវះកាត់ដោះចេញរួច ឬអាចធ្វើតាមក្រោយមកទៀត។ ពិភាក្សាជាមួយគ្រូពេទ្យរបស់អ្នកអំពីជំរើសប្រសើរបំផុតសំរាប់អ្នក។

សូមពិភាក្សាជាមួយអ្នកផ្តល់ការថែទាំសុខភាពរបស់អ្នកអំពីសំនួរនានា ឬកង្វល់ផ្សេងៗដែលអ្នកមាន។

**A project by Health Roads Media and EthnoMed**
This project has been funded in whole or in part with Federal funds from the Department of Health and Human Services, National Institutes of Health, National Library of Medicine, under Contract No. HHS-N-276-2011-0008-C with the University of Washington.
Thank you to Safeway Foundation for its support to Harborview Medical Center's EthnoMed for the development of cancer-related content.